## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចព្រមព្រៀង

រវាង

ពោងចក្រ ក្រុមហ៊ុនស្មាតសាញ ហ្គាមិន (ខេមបូឌា) ឯ.ក

និង

ដំណាងប្រតិភូបុគ្គលិក ប្រចាំពោងចក្រក្រុមហ៊ុនស្មាតសាញ ហ្គាមិន (ខេមបូឌា) ឯ.ក ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៩ ខែមិនា ឆ្នាំ២០២៣ វេលាម៉ោង ១៤:០០នាទីរសៀល នៅពោងចក្រ **ក្រុមហ៊ុនស្មាតសាញ ហ្គាមិន (ខេមបូឌា) ឯ.ក**មានកិច្ចប្រជុំមួយ រវាងដំណាងក្រុមហ៊ុន និងដំណាងកម្មករនិយោជិតប្រចាំពោងចក្រ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុន និងដំណាងកម្មករនិយោជិតទាំងអស់យល់ពីស្ថានភាពបច្ចុប្បន្ននៅក្នុងពោងចក្រ ដោយសារតែក្រុមហ៊ុនយើងខ្ញុំមិនមានការបញ្ជាទិញគ្រប់គ្រាន់ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់ពោងចក្រទាំងមូលដំណើរការបាន ហេតុនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិតក្នុងចំណោមកម្មករសរុបចំនួន**២២៦**នាក់(ស្រីចំនួន**១៨៦**នាក់) ស្ថិតក្នុងកិច្ចសន្យាការងារមានថេរវេលាកំណត់ចំនួន **១២៤**នាក់ ក្នុងរយៈពេលចំនួន២ខែ គឺចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៣រហូតដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវ ប្រាក់ឈ្នួលចំនួន ៣០ដុល្លារ និង ចំនួន ៤០ដុល្លារ ពីរដ្ឋាភិបាល ក្នុង១ខែ សម្រាប់កម្មករ និយោជិតម្នាក់ៗ

អង្គប្រជុំបានចប់វេលាម៉ោង ១៤:៣០នាទីរសៀល នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងល្អូន។

កំពង់ស្ពឺ.ថ្ងៃទី២៩ ខែមិនា ឆ្នាំ ២០២៣

ហត្ថលេខា និងត្រា

ម្ចាស់ បុនាយក

ក្រុមហ៊ុន ស្មាត សាញ ហ្គាមិន (ខេមបូឌា) ឯ.ក
SMART SHINE GARMENT (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

តំណាងកម្មករ